# ឃ្លាំមើលសភា និង តំណាងរាស្ត្រសំរាប់ខែកញ្ញា ឆ្នាំ២០០៧

នៅក្នុងខែនេះ រដ្ឋសភាបានបើកសម័យប្រជុំវិសាមញ្ញដែលមានរយៈពេល ៦ ព្រឹក ដើម្បីពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់មួយចំនួន និងប្រកាសសុពលភាពអ្នកតំណាងរាស្ត្រថ្មី។ សម័យប្រជុំវិសាមញ្ញនេះបានធ្វើឡើងបន្ទាប់ពីមានការរិះគន់សារជាថ្មីពីនាយករដ្ឋមន្ត្រី **សម្តេច ហ៊ុន សែន** ថាសភានៅជំពាក់ច្បាប់រដ្ឋាភិបាលជាច្រើន។ ក្នុងខែនេះដែរ **ខុមហ្វ្រែល** សង្កេតឃើញថា ការតាមបន្តជួយអន្តរាគមន៍របស់អ្នកតំណាងរាស្ត្រទៅកាន់អាជ្ញាធរវៀតណាមចំពោះករណីអតីតព្រះសង្ឃ **ទីម សាខន** កំពុងតែទទួលបានផលមួយចំនួន។ ដោយឡែកការចុះទៅកាន់មូលដ្ឋានដោយអ្នកតំណាងរាស្ត្រ **ខុមហ្វ្រែល**សង្កេតឃើញថា មណ្ឌលដែលមានអ្នកតំណាងរាស្ត្រចុះទៅច្រើននៅតែនាំមុខ ខណៈដែលមណ្ឌលដែលមានតំណាងរាស្ត្រចុះទៅតិចតួចនៅតែតិចតួចដដែល។ **ខុមហ្វ្រែល** ទទួលបានព័ត៌មានថា មានអ្នកតំណាងរាស្ត្រយ៉ាងហោចណាស់ ចំនួន **៤១រូប** បានចុះទៅកាន់មូលដ្ឋានយ៉ាងតិចចំនួន **១៣៧**លើក។

## ការចុះនៅកាន់មណ្ឌលនានារបស់អ្នកតំណាងរាស្ត្រ

ក្រាហ្វិចទី១: ភាគរយអ្នកតំណាងរាស្ត្រចុះមូលដ្ឋាន នៃគណបក្សនីមួយៗធៀបនឹងគណបក្សរបស់ខ្លួន




គោលបំណងរបស់អ្នកតំណាងរាស្ត្រចុះទៅកាន់មូលដ្ឋានមានដូចជា **ចុះជួយដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋ ចូលរួមក្នុងវេទិកា ចុះអមដំណើរថ្នាក់ដឹកនាំ ចុះពង្រឹងបណ្តាញគណបក្ស** និងជាពិសេស **ចុះសួរសុខទុក្ខ និងចែកអំណោយ** ហើយអ្នកតំណាងរាស្ត្រមួយចំនួន ក៏បានចុះទៅមូលដ្ឋានដើម្បីចូលពិធីបុណ្យកាន់បិណ្ឌផងដែរ នៅខណៈដែលពិធីបុណ្យកាន់បិណ្ឌបានចាប់ផ្តើមកាលពីចុងខែកញ្ញានេះ។ **មណ្ឌលបាត់ដំបង** នៅតែមានអ្នក-តំណាងរាស្ត្រចុះច្រើនជាងគេរហូតដល់ចំនួន **៦៣ លើក**។ ចំណែកមណ្ឌលដែលខុមហ្វ្រែលមិនបានទទួលព័ត៌មាន ឬមិនមានព័ត៌មានអំពីការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្ររួមមានមណ្ឌល **មណ្ឌលគិរី ស្ទឹងត្រែង និង ឧត្តរមានជ័យ**។ **ខុមហ្វ្រែល** សង្កេតឃើញថា ទាំងចំនួនអ្នកតំណាងរាស្ត្រ និងចំនួនលើកដែលបានចុះមូលដ្ឋានបានធ្លាក់ចុះបើប្រៀបទៅនឹងខែសីហា ដោយមានការលើកឡើងថាអ្នកតំណាងរាស្ត្រជាប់ប្រជុំនៅភ្នំពេញ។ អ្នកតំណាងរាស្ត្រមកពីគណបក្ស**ប្រជាជនកម្ពុជា** យ៉ាងតិចចំនួន **២៥រូប** (ស្មើនឹង ៣៤%នៃអ្នកតំណាងរាស្ត្រ គណបក្សនេះទាំងអស់ដែលមានចំនួន ៧៣រូប) បានចុះទៅកាន់មូលដ្ឋានយ៉ាងតិចចំនួន **៩៧លើក** ចំណែកតំណាងរាស្ត្រគណបក្ស **សមរង្ស៊ី** យ៉ាងតិចចំនួន **១២ រូប** (ស្មើនឹង ៥០% នៃអ្នកតំណាងរាស្ត្រគណបក្សនេះទាំងអស់ដែលមានចំនួន ២៤រូប) បានចុះមូលដ្ឋានយ៉ាងតិចចំនួន **៣១លើក** ហើយអ្នកតំណាងរាស្ត្រគណបក្ស **ហ៊្វុនស៊ិនប៉ិច** យ៉ាងតិចចំនួន **៤ រូប** (ស្មើនឹង ១៥% នៃអ្នកតំណាងរាស្ត្រ គណបក្សនេះទាំងអស់ ដែលមានចំនួន ២៦រូប) បានចុះមូលដ្ឋានយ៉ាងតិចចំនួន **៩លើក**។

**តារាងទី១:** ចំនួនលើកនៃការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រតាមគោលបំណងផ្សេងៗដែលខុមហ្វ្រែលទទួលបាន

| **គោលបំណងនៃការចុះមូលដ្ឋាន ទាំង ១៣៧លើកនៃអ្នកតំណាងរាស្ត្រទាំង ៤១រូប** | **គណបក្សនយោបាយ** | | | **សរុបនៃគោលបំណង** |
|---|---|---|---|---|
| | ២៥រូប | ១២រូប | ៤រូប | |
| សាកសួរសុខទុក្ខ ចែកអំណោយនិង ការសម្ពោធសមិទ្ធផលនានា | ៦២ | ១១ | ៥ | ៧៨ (៥៧%) |
| ការចុះពង្រឹងផ្ទៃក្នុង និង បណ្តាញគណបក្ស | ១០ | ៩ | ០ | ១៩ (១៤%) |
| ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ | ១៩ | ៥ | ០ | ២៤ (១៨%) |
| ការចូលរួមក្នុងវេទិកាសាធារណៈ | ៥ | ៤ | ៤ | ១៣ (៩%) |
| ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា | ១ | ២ | ០ | ៣ (២%) |
| **សរុប ជាភាគរយតាមគណបក្ស** | ៩៧ (៧១%) | ៣១ (២៣%) | ៩ (៦%) | ១៣៧ (១០០%) |

តារាងទី១ បានបង្ហាញថា:

- **ការសាកសួរសុខទុក្ខ ចែកអំណោយ និងការសម្ពោធសមិទ្ធផលនានា:** ខុមហ្វ្រែលសង្កេតឃើញថាការចុះទៅកាន់មណ្ឌលរបស់អ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជា នៅតែផ្តោតខ្លាំងទៅលើ **ការសាកសួរសុខទុក្ខ ចែកអំណោយ....**។ បើទោះបីជា **សកម្មភាពនេះត្រូវបានធ្វើឡើងដោយអ្នកតំណាងរាស្ត្រទាំងបីគណបក្សដែលមានចំនួន ៧៨លើក (ស្មើនឹង ៥៧% នៃការចុះទៅកាន់មូលដ្ឋានសរុប)** ក៏ដោយ តែអ្នកតំណាងរាស្ត្រមកពីគណបក្ស ប្រជាជនកម្ពុជាមានរហូតដល់ចំនួន **៦២លើក** ដូចជាការចុះមូលដ្ឋានរបស់អ្នកតំណាងរាស្ត្រ **សៀង ណាំ** មណ្ឌល សៀមរាប ដើម្បីចែកអំណោយដល់ពលរដ្ឋមានសារុង និងបើកការដ្ឋានជួសជុលផ្លូវពីផ្សារដំដែកទៅកាន់ឃុំ **ដានរុន** ប្រវែង ១៣ គីឡូម៉ែត្រ។
- **ការចុះពង្រឹងផ្ទៃក្នុង និងបណ្តុញគណបក្ស:** ទោះបីសកម្មភាពនេះត្រូវបាននាំមុខដោយអ្នកតំណាងរាស្ត្រគណបក្សប្រជាជនកម្ពុជាដែលមានចំនួន ១០ លើកក៏ដោយ **ខុមហ្វ្រែល**សង្កេតឃើញថា បើប្រៀបធៀបគោលបំណងតាមគណបក្សនីមួយៗ តំណាងរាស្ត្រគណបក្ស **សមរង្ស៊ី នៅតែផ្តោតខ្លាំងទៅលើការចុះពង្រឹងផ្ទៃក្នុង និងបណ្តុញគណបក្ស** ដោយសកម្មភាពនេះមានចំនួន **៩លើក** ប្រហែលនឹងសកម្មភាព ចុះសាកសួរសុខទុក្ខ ចែកអំណោយ.....។ ចំណែកតំណាងរាស្ត្រមកពីគណបក្ស ហ៊្វុនស៊ិនប៉ិច ខុមហ្វ្រែល មិនបានទទួលព័ត៌មានថាបានចុះពង្រឹងផ្ទៃក្នុង និងបណ្តុញគណបក្សរបស់ខ្លួនទេ។
- **ការចុះអមដំណើរជាក្រុម ឬអមដំណើរថ្នាក់ដឹកនាំ** មានចំនួន **២៤លើក ស្មើនឹង ១៨%**នៃចំនួនការចុះទៅកាន់មូលដ្ឋានសរុប។ សកម្មភាពនេះត្រូវបាននាំមុខ ដោយ**គណបក្សប្រជាជនកម្ពុជា** ដែលមានចំនួនរហូតដល់ **១៩ លើក**។ អ្នកតំណាងរាស្ត្រគណបក្ស **សមរង្ស៊ី** អមដំណើរថ្នាក់ដឹកនាំរបស់ខ្លួនចំនួន **៥លើក** ចំណែកគណបក្សហ៊្វុនស៊ិនប៉ិច **ខុមហ្វ្រែល**មិនបានទទួលព័ត៌មានថាមានអ្នកតំណាងរាស្ត្រចុះអមដំណើរថ្នាក់ដឹកនាំទេ។
- **ការចូលរួមក្នុងវេទិកាសាធារណ:** ដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលត្រូវបានអ្នកតំណាងរាស្ត្រចូលរួមចំនួន **១៣លើក ស្មើនឹង ៩%** នៃចំនួនការចុះទៅកាន់មូលដ្ឋានសរុប។ សកម្មភាពនេះត្រូវបានចូលរួមដោយអ្នកតំណាងរាស្ត្រមកពីគណបក្សទាំង ៣ ប្រហាក់ប្រហែលគ្នា ដោយគណបក្ស **ប្រជាជនកម្ពុជា ៥លើក ហ៊្វុនស៊ិនប៉ិច**ចំនួន ៤លើក គណបក្ស និងគណបក្ស **សមរង្ស៊ី** ៤លើក។ នៅថ្ងៃទី ១៦ ខែ កញ្ញា នៅខេត្តកំពង់ស្ពឺ អ្នកតំណាងរាស្ត្រទាំងបីគណបក្សរួមមានអ្នកតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ **លី សុន អ្នកតំណាងរាស្ត្រ នុត រំដួល និងអ្នកតំណាងរាស្ត្រ គង់ ហាច** បានចូលរួមជាវាគ្មិនក្នុងវេទិកាតំណាងរាស្ត្រ និងម្ចាស់ឆ្នោត ដែលរៀបចំឡើងដោយវិទ្យាស្ថានជាតិប្រជាធិបតេយ្យ។
- **ការអន្តរាគមន៍ និងដោះស្រាយបញ្ហានានា** នៅតែត្រូវបានអ្នកតំណាងរាស្ត្រ យកចិត្តទុកដាក់តិចជាងគេបំផុតត្រឹមតែ **៣លើក ស្មើនឹង ២%** នៃការចុះទៅកាន់មូលដ្ឋានសរុប បើទោះបីជាប្រជាពលរដ្ឋនៅតែជួបប្រទះបញ្ហាជាច្រើនក៏ដោយ។ អ្នកតំណាងរាស្ត្រមកពីគណបក្ស **សមរង្ស៊ី** បាននាំមុខគេក្នុងការធ្វើការអន្តរាគមន៍ដែលមានចំនួន **២លើក**។ ឧទាហរណ៍ កាលពីថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៧ អ្នកតំណាងរាស្ត្រ **សុន ឆៃ** មណ្ឌលភ្នំពេញបានចុះជួយអន្តរាគមន៍វិវាទដីធ្លីក្នុងឃុំជីខលើ និងឃុំជីខក្រោម ស្រុកស្រែអំបិល **ខេត្តកោះកុង**។ អ្នកតំណាងរាស្ត្រមកពីគណបក្ស **ប្រជាជនកម្ពុជា** ចំនួន **១លើក**។ ខុមហ្វ្រែលមិនបានទទួលព័ត៌មានស្តីពីការចុះអន្តរាគមន៍របស់តំណាងរាស្ត្រមកពីគណបក្សហ៊្វុនស៊ិនប៉ិចទេ។

## សង្ខេបព្រឹត្តិការណ៍សំខាន់ៗទាក់ទិនសភា និង តំណាងរាស្ត្រ

### តំណាងរាស្ត្ររងការចោទប្រកាន់យកពេលប្រជុំសភាធ្វើយុទ្ធនាការឃោសនារកសម្លេងឆ្នោត

មន្ត្រីជាន់ខ្ពស់ក្នុងរាជរដ្ឋាភិបាល និងសមាជិកសភាមកពីគណបក្ស **ប្រជាជនកម្ពុជា** បាននាំគ្នាចោទអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** ដែលជាប្រធានគណបក្ស **សមរង្ស៊ី** ថាបានយកពេលវេលាពិភាក្សាច្បាប់មកធ្វើជាយុទ្ធនាការឃោសនាសំរាប់គណបក្សខ្លួន។

ការចោទប្រកាន់នេះបានធ្វើឡើង បន្ទាប់ពីអ្នកតំណាងរាស្ត្រ **សម រង្ស៊ី** បានប្រកាសក្នុងសភាថា គណបក្ស សមរង្ស៊ី នឹងមិនគាំទ្រសេចក្តីព្រាងច្បាប់ស្តីពីសម្បទាន ដោយសារតែវាមានលក្ខណៈមិនពេញលេញ ប៉ះពាល់ដល់សិទ្ធិ និងជីវភាពរបស់ប្រជាពលរដ្ឋ និងបានវាយប្រហារខ្លាំងៗទៅលើរាជរដ្ឋាភិបាលពីបញ្ហាពុករលួយ និងទុក្ខវេទនារបស់ប្រជាពលរដ្ឋដោយសារការផ្តល់សម្បទានដីទៅឱ្យក្រុមហ៊ុនមួយចំនួន។

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ **គាត ឈន់** ដែលបានមកការពារសេចក្តីព្រាងច្បាប់បានឆ្លើយថា សម្តីទាំងនេះគឺដើម្បីឃោសនាបោះឆ្នោត "*អារម្មណ៍របស់លោក* [សម រង្ស៊ី] *ក្នុងការអន្តរាគមន៍គ្មានទេ អារម្មណ៍គិតតែថ្ងៃ ២៨ កក្កដា ២០០៨* [ក្រោយការបោះឆ្នោតជ្រើសរើសតំណាង-រាស្ត្រមួយថ្ងៃ] *ពេកទៅ*។

## នាយករដ្ឋមន្ត្រីរិះគន់ពីពេលវេលាធ្វើការរបស់អ្នកតំណាងរាស្ត្រសារជាថ្មី

នាយករដ្ឋមន្ត្រី សម្តេច **ហ៊ុន សែន** បានរិះគន់ជាថ្មីម្តងទៀតទៅលើល្បឿនការងាររបស់អ្នកតំណាងរាស្ត្រក្នុងការអនុម័តច្បាប់ បន្ទាប់ពីស្ថាប័នកំពូលមួយនេះមានអាគារថ្មីដែលត្រូវបានចាត់ទុកថាជាសំណង់ប្រវត្តិសាស្ត្រជាតិសម្រាប់សតវត្សទី ២១។

ការរិះគន់នេះបានធ្វើឡើងនៅក្នុងវេទិកាផ្នែករដ្ឋាភិបាល-ឯកជនកម្ពុជាលើកទី ១២។ សម្តេច **ហ៊ុន សែន** បានមានប្រសាសន៍ថា "*អាគារសភាល្អហើយ គឺយើងគួរតែប្រជុំព្រឹកផង ល្ងាចផង ព្រោះឥឡូវនៅសភា ជំពាក់ច្បាប់រដ្ឋាភិបាលច្រើនពេកហើយ។*" សម្តេច **ហ៊ុន សែន** ក៏បានថ្លែងពីក្តីបារម្ភផងដែរថា រដ្ឋសភានីតិកាលទី៣ មិនអាចអនុម័តអស់នូវច្បាប់ទាំងឡាយរបស់រាជរដ្ឋាភិបាល ហើយបញ្ជូនមករាជរដ្ឋាភិបាលវិញ សម្រាប់នីតិកាលទី៤ ដែលនេះគឺជាការបញ្ជូនត្រឡប់ទៅត្រឡប់មក។

ប្រធានរដ្ឋសភា សម្តេច **ហេង សំរិន** ធ្លាប់បានបកស្រាយប្រាប់អ្នកសារព័ត៌មានថា **ភាពយឺតយ៉ាវនៃការអនុម័តច្បាប់ក៏ដោយសារតែតំណាងរាជរដ្ឋាភិបាលមកពិភាក្សានៅគណៈកម្មការជំនាញមានការយឺតយ៉ាវផងដែរ**។

នៅក្នុងខែ កញ្ញា នេះ តាមព័ត៌មានដែលខុមហ្វ្រែលទទួលបាន មានសេចក្តីព្រាងច្បាប់ថ្មីចំនួន ៣ ដែលគណៈកម្មការជំនាញសភាទទួលបាន និងបានពិភាក្សា។

សម្តេច **ហ៊ុន សែន** កន្លងមកធ្លាប់បានស្នើឱ្យសភាធ្វើការប្រជុំទាំងព្រឹក ថ្ងៃ និងអាចដល់យប់នៅពេលផ្លាស់ទៅវិមានរដ្ឋសភាថ្មី ទោះបីយ៉ាងណារហូតមកដល់ពេលនេះ **ខុមហ្វ្រែល** សង្កេតឃើញថាសភាមិនដែលប្រជុំរហូតដល់ពេលល្ងាចនោះទេ។

**ខុមហ្វ្រែល** យល់ឃើញថានៅខណៈដែលការថែមពេលវេលាធ្វើការជាការសំខាន់មួយសម្រាប់បង្កើនល្បឿនការងារ រាជរដ្ឋាភិបាលក៏គួរបង្កើនល្បឿនធ្វើសេចក្តីព្រាងច្បាប់ ជាពិសេសច្បាប់សំខាន់ៗសម្រាប់ពង្រឹងប្រព័ន្ធយុត្តិធម៌ និងប្រឆាំងអំពើពុករលួយ ដាក់ជូនគណៈកម្មការជំនាញរបស់សភាសម្រាប់ការពិភាក្សា។ ទន្ទឹមនឹងនេះ ខុមហ្វ្រែលក៏យល់ឃើញដែរថាអ្នកតំណាងរាស្ត្រនីមួយៗ បន្ទាប់ពីមានបន្ទប់ផ្ទាល់ខ្លួនប្រកបដោយផាសុកភាព គួរតែពង្រឹងសមត្ថភាព និងប្រសិទ្ធភាពការងាររបស់ខ្លួនតាមរយៈសិក្សាអត្ថបទដែលនឹងត្រូវពិភាក្សា ដោយស្រាវជ្រាវទៅលើឯកសារច្បាប់បរទេសផ្សេងៗដែលទាក់ទង។ ខុមហ្វ្រែលសង្ឃឹមថា អ្នកតំណាងរាស្ត្រទាំងអស់ នៅពេលពិភាក្សា ក៏ដូចជាផ្តល់អនុសាសន៍ទៅលើសេចក្តីព្រាងច្បាប់ នឹងផ្តោតទៅលើលក្ខណៈបច្ចេកទេសនៃច្បាប់ ជាជាងលក្ខណៈនយោបាយ។

## អ្នកតំណាងរាស្ត្រ សុន ឆៃ បន្តអន្តរាគមន៍ជួយដល់អតីតព្រះចៅអធិការវត្តភ្នំដិន ព្រះនាម ទីម សាខន

ការជួយអន្តរាគមន៍ជាបន្តបន្ទាប់ដោយអ្នកតំណាងរាស្ត្រមកពីគណបក្សជំទាស់ និងសមាគមខ្មែរកម្ពុជាក្រោមនានាទៅលើ ករណីរឿងលោក **ទីម សាខន** ខ្មែរកម្ពុជាក្រោមដែលត្រូវបានអាជ្ញាធរវៀតណាមឃុំក្នុង **ពន្ធនាគារនៅវៀតណាម** ឃើញបានលទ្ធផលល្អមួយចំនួន។

អ្នកតំណាងរាស្ត្រ សុន ឆៃ ប្រធានគណៈកម្មការទី ៥ ទទួលកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាននៃរដ្ឋសភា បានប្រាប់វិទ្យុអាស៊ីសេរីថា ប្រទេសវៀតណាមបានអនុញ្ញាតឱ្យគ្រួសាររបស់លោក ទីម សាន ចូលសួរសុខទុក្ខលោក ទីម សាខន ហើយប្រទេសវៀតណាមបានសន្យាមិនធ្វើបាបលោក ទីម សាខននោះទេ។ លោក សុន ឆ័យ បានមានប្រសាសន៍ថា "*ស្ថានទូតវៀតណាមបានសន្យាជាមួយខ្ញុំថា គេនឹងមិនធ្វើទុក្ខបុកម្នេញ ឬក៏ធ្វើទារុណកម្មអីចំពោះលោក ទីម សាខន ទេ។*"

គណៈកម្មការទី៥នៃរដ្ឋសភាកម្ពុជា នឹងត្រូវជួបពិភាក្សាជាមួយគណៈប្រតិភូសភាមកពីវៀតណាមនៅដើមខែតុលា ហើយការពិភាក្សានេះនឹងមិនលើកឡើងពីករណីលោក ទីម សាខន នោះទេ បើទោះបីជាមានកិច្ចប្រឹងប្រែងពីអ្នកតំណាងរាស្ត្រ សុន ឆៃ ឱ្យមានការពិភាក្សាពីករណីលោក ទីម សាខន ក៏ដោយ។

គួររំលឹកដែរថា ករណីលោក ទីម សាខន ត្រូវបានតំណាងរាស្ត្រមកពីគណបក្សជំទាស់មួយចំនួនបានធ្វើការអន្តរាគមន៍ជាបន្តបន្ទាប់ ចាប់តាំងពីមានព័ត៌មានថា អតីតព្រះចៅអធិការវត្តភ្នំដិន នៅក្នុងខេត្ត តាកែវ រូបនេះត្រូវបានជាប់ឃុំនៅក្នុងពន្ធនាគារប្រទេសវៀតណាម។

## សេចក្តីព្រាងច្បាប់ស្តីពី សម្បទាន ត្រូវបានអនុម័តដោយមានមតិចម្រូងចម្រាស់

សេចក្តីព្រាងច្បាប់ស្តីពី សម្បទាន ត្រូវបានរដ្ឋសភាអនុម័តដោយគ្មានការកែប្រែខ្លឹមសារឡើយ បើទោះបីជាមានការលើកឡើងពីអ្នកតំណាងរាស្ត្រមួយចំនួនថាច្បាប់នេះមិនពេញលេញ ខ្វះតម្លាភាព ដែលអាចនាំឱ្យប៉ះពាល់ដល់សិទ្ធិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

អ្នកតំណាងរាស្ត្រ សម រង្ស៊ី និងមោញ សាផាន មណ្ឌលកំពង់ចាមបានថ្លែងថាគួរមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋដែលពាក់ព័ន្ធ។

អ្នកតំណាងរាស្ត្រ សម រង្ស៊ី បានឱ្យដឹងទៀតថា កន្លងមករដ្ឋាភិបាលបានផ្ដល់ដីសម្បទានដល់ក្រុមហ៊ុនឯកជន មិនដែលបានពិភាក្សា ឬសួរយោបល់ពលរដ្ឋនៅកន្លែងនោះទេ។

ការដាក់ទណ្ឌកម្មបុគ្គលល្មើសនឹងបទប្បញ្ញត្តិច្បាប់នេះ ក៏ត្រូវបានអ្នកតំណាងរាស្ត្រយល់ថាមិនច្បាស់លាស់ដែរ។ អ្នកតំណាងរាស្ត្រ ម៉ោញ សាផាន បានថ្លែងថា "*វាគ្មានបទល្មើសណាដែលច្បាប់អត់ចែងទេ។ បទល្មើសសុទ្ធតែមានច្បាប់ចែង ទើបយើងយកមកផ្ដន្ទាទោសបាន។ ហើយវាគ្មានទោសណាដែលច្បាប់អត់ចែងទេ ទាល់តែច្បាប់ចែងថាមានទោសទើបគេយកមកផ្ដន្ទាទោសបាន* "។

យោងតាមមាត្រា៤២ នៃសេចក្ដីព្រាងច្បាប់នេះបានឱ្យដឹងថា បុគ្គលណាល្មើសនឹងបទប្បញ្ញត្តិច្បាប់នេះត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ហើយមន្ត្រីរាជការដែលប្រព្រឹត្តល្មើស ឬធ្វេសប្រហែសដោយចេតនាក្នុងការបំពេញតួនាទីរបស់ខ្លួន ពាក់ព័ន្ធការងារសម្បទានត្រូវបានទទួលទណ្ឌកម្ម ពិន័យរដ្ឋបាលថែមទៀតស្របតាមសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះមានវិសាលភាពគ្រប់គ្រងសម្បទានទាំងឡាយដែលមានទំនាក់ទំនងទៅនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្គត់ផ្គង់សេវាដោយផ្ទាល់ ឬដោយប្រយោលដើម្បីប្រយោជន៍សាធារណៈ ។

## <u>ការផ្លាស់ប្ដូរសមាជិកសភា</u>

ក្នុងសម័យប្រជុំវិសាមញ្ញក្នុងខែនេះ មានការផ្លាស់ប្ដូរសមាជិកសភាចំនួនពីររូបមកពីគណបក្ស ប្រជាជនកម្ពុជា និងគណបក្ស សមរង្ស៊ី ។



ឯ. កែវ រ៉េមី



ឯ. នូ សុវត្ថិ

គណបក្ស **សមរង្ស៊ី** បានផ្លាស់ប្ដូរសមាជិកសភាមកពីគណបក្សរបស់ខ្លួន អ្នកតំណាងរាស្ត្រ **កែវ រ៉េមី** ក្រោមហេតុផលប្រាសចាកសមាជិកភាពពីគណបក្ស។

អ្នកតំណាងរាស្ត្រ **កែវ រ៉េមី** មណ្ឌល ភ្នំពេញបានប្រកាសពីការលាឈប់ពីគណបក្ស សមរង្ស៊ី ទៅចុះចូលជាមួយគណបក្ស សិទ្ធិមនុស្ស នៅសម័យប្រជុំសភាពេញអង្គនៅខែ មិថុនា ឆ្នាំ២០០៧។ ក្រោយមកសភាបាន ប្រកាសតែងតាំងឯកឧត្ដម **នូ សុវត្ថិ** ជំនួសអ្នកតំណាងរាស្ត្រ កែវ រ៉េមី នៅក្នុងសម័យប្រជុំវិសាមញ្ញ ក្នុងខែ កញ្ញា នេះ តាមការស្នើសុំរបស់គណបក្សសមរង្ស៊ី ។



ឯ. ឯក សំអុល

គណបក្សប្រជាជនកម្ពុជា ក៏បានដោះដូរអ្នកតំណាងរាស្ត្រ **ឯក សំអុល** មណ្ឌលព្រៃវែងជំនួស ដោយឯកឧត្ដម **សុខ សាយ** នៅក្នុងសម័យប្រជុំវិសាមញ្ញនេះដែរ ដោយសារតែអ្នកតំណាងរាស្ត្រ ឯក សំអុល ត្រូវបានសភាបោះឆ្នោតជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៅខែ មិថុនា ឆ្នាំ ២០០៧ ដែលតម្រូវឱ្យអ្នកតំណាងរាស្ត្រ ឯក **សំអុល** ត្រូវលាឈប់ពីសមាជិកសភា។ មានសំណួរលើកឡើងថា ហេតុអ្វីក៏ត្រូវធ្វើការផ្លាស់ប្ដូរអ្នកតំណាងរាស្ត្រ **ឯក សំអុល** ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ ខណៈដែលអ្នកតំណាងរាស្ត្ររូបនេះមានភាពសកម្មយ៉ាងខ្លាំងក្នុងការបញ្ចេញមតិយោបល់ល្អៗទៅលើសេចក្ដីព្រាងច្បាប់ ហើយការផ្លាស់ប្ដូរនេះអាចធ្វើឱ្យបាត់បង់ធនធានដ៏ល្អមួយរូបសំរាប់ស្ថាប័ននីតិបញ្ញត្តិ។ អ្នកតំណាងរាស្ត្រ **ឯក សំអុល** ធ្លាប់ជាប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា ក្រោយមកត្រូវបានជំនួសដោយអ្នកតំណាងរាស្ត្រ **ប៉ែន បញ្ញា** មុននឹងមានការបោះឆ្នោតជ្រើសរើសធ្វើជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញានឹងក្រោយមកត្រូវបានជាប់ឆ្នោតជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។

សម្ព័ន្ធអង្គការសង្គមស៊ីវិលធ្លាប់បានពន្យល់ថា **សិទ្ធិរបស់អ្នកតំណាងរាស្ត្រមានការចុះខ្សោយនិងស្ថិតនៅក្រោមឥទ្ធិពលនៃគណបក្សនយោបាយ** ដោយសារតែការអនុវត្តន៍ **មាត្រា១២០នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រ** ដែលចែងថា **សមាជិករដ្ឋសភាបាត់បង់សមាជិកភាពនៅពេល** សាមីខ្លួន **បាត់បង់សមាជិកភាពពីគណបក្សនយោបាយ** ។

**អង្គការសង្គមស៊ីវិល និងអ្នកតំណាងរាស្ត្រមួយចំនួនក៏បានទទូចហើយទទូចទៀតឱ្យធ្វើវិសោធនកម្មមាត្រា** ១២០នេះ ដោយ**សមាជិកភាព អ្នកតំណាងរាស្ត្រ មិនត្រូវបាត់បង់ដោយសារតែការប្រាសចាកសមាជិកភាពពីគណបក្សនយោបាយ**នោះទេ។

# ការអនុម័តនានាដោយរដ្ឋសភា

នៅក្នុងសម័យប្រជុំវិសាមញ្ញដែលមានរយៈពេល ៦ព្រឹក រដ្ឋសភាបានពិភាក្សា និងអនុម័តរបៀបវារៈចំនួន ០៨ រួមមានសេចក្តីព្រាងច្បាប់ និងរបៀបវារៈផ្សេងៗដូចជាៈ

- ការបោះឆ្នោតទុកចិត្តលើការតែងតាំង ឯកឧត្តម **ប៊ិន ឈិន** ជាឧបនាយករដ្ឋមន្ត្រី ឯកឧត្តម **វេង សិរីវុឌ្ឍ** ជាទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោកជំទាវ **ចាន់ សុទ្ធាវី** ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ និង អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ តេហ្ស** ជារដ្ឋលេខាធិការក្រសួងទេសចរណ៍
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការ **អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងពិធីសារឆ្នាំ១៩៧២ ដែលបានធ្វើវិសោធនកម្មអនុសញ្ញាទោលស្តីពីគ្រឿងញៀន ឆ្នាំ ១៩៦១**
- ការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី **ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាង រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ស្តីពីការជំរុញនិងការការពារវិនិយោគ**
- ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី **សម្បទាន**
- ការពិភាក្សានិងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី **ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។**

***********************************